តុលាការខេត្តកណ្តាល

<u>សំណុំរឿងព្រហ្មទណ្ឌ</u>

លេខ ៣៦ អក ចុះថ្ងៃទី ២២

ខែ មីនា ឆ្នាំ ១៩៩៣

ជំនុំជំរះលេខ ៣៣

ចុះថ្ងៃទី ៣១ ខែ សីហា

ឆ្នាំ ១៩៩៥

<u>សាលក្រម</u>

លេខ ៣៣ ចុះថ្ងៃទី ៣១

ខែ សីហា ឆ្នាំ ១៩៩៥

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**តាងនាមប្រជារាស្ត្រខ្មែរ**

**តុលាការខេត្តកណ្តាល**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈនៅនាទីតុលាការខេត្តកណ្តាល នៅថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩៥ ដោយសមាសភាពដូចតទៅ :

**<u>ចៅក្រមជំនុំជំរះ</u>**

លោក [redacted] ចៅក្រមតុលាការខេត្តកណ្តាល

**<u>តំណាងអយ្យការ</u>**

លោក [redacted] ព្រះរាជអាជ្ញាអមតុលាការខេត្តកណ្តាល

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted] ក្រឡាបញ្ជីតុលាការខេត្តកណ្តាល

**<u>ដើម្បីជំនុំជំរះ</u>**

១-ជនជាប់ចោទឈ្មោះ **ភ ចន** ភេទប្រុស អាយុ ១៩ឆ្នាំ ជាតិខ្មែរ សញ្ជាតិកម្ពុជា ទីលំនៅកំណើត និង បច្ចុប្បន្នភូមិព្រៃកប្បសី ឃុំព្រៃកប្បសី ស្រុកតាខ្មៅ ខេត្តកណ្តាល ។ មុខរបរសិស្ស ឪពុកឈ្មោះ **ភ ឈន** (រ) ម្តាយឈ្មោះ **អ សផ** (រ) នៅលីវ ទោសពីមុន *គ្មាន* ។

ត្រូវចោទពីបទ : <u>បង្ករបួសស្នាម</u> ប្រព្រឹត្តនៅភូមិព្រៃកប្បសី ឃុំព្រៃកប្បសី ស្រុកតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង អោយផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

**<u>រឿងហេតុមានដូចតទៅ</u>** :

កាលពីថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩២ គ្រួសាររបស់ឈ្មោះ **អ សគ** បានដុតសំរាមនៅលើដីរបស់ខ្លួនបណ្តាលអោយហុយផ្សែងចូលទៅផ្ទះរបស់ឈ្មោះ **អ ស** ក៏កើតមានទំនាស់ជេរបញ្ចោរគ្នាទៅវិញទៅមកព្រមទាំងយកដុំដី និង ដុំថ្មគប់គ្នាពីផ្ទះមួយទៅផ្ទះមួយផង រហូតដល់ម៉ោងប្រហែល ១០ព្រឹកថ្ងៃ ខែ ឆ្នាំដដែល ឈ្មោះ **ភ ឈន** ជាប្តីរបស់ឈ្មោះ **អ សផ** និង ឈ្មោះ **ភ ចន** ជាកូនបានត្រលប់ពីធ្វើការមកផ្ទះវិញ ឈ្មោះ **ភ សផ** ដែលត្រូវជាប្អូនបាននិយាយរឿងរ៉ាវឈ្លោះគ្នានោះប្រាប់ ។ ពេលបានទទួលដំណឹងនេះភ្លាមស្រាប់តែឈ្មោះ **ភ ឈន** និង ឈ្មោះ **ភ ចន** ដើរទៅផ្ទះរបស់ឈ្មោះ **អ សគ** ដើម្បី

*សាលក្រមនេះចូលជាស្ថាពរពីថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៩៦ តទៅ*

*ដោយភាគីពុំបានចូលមកប្តឹងតវ៉ា តាមកំណត់ច្បាប់ឡើយ ។*

*កណ្តាល,ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៩៥*

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានតុលាការ**

[redacted]

សូរនាំរឿងហេតុ ពេលនេះក៏កើតមានការវាយតប់គ្នាទៅវិញទៅមក ។ ពេលវាយតប់គ្នានោះឈ្មោះ ភ ចន បានវាយឈ្មោះ អ សភ មួយដៃចំភ្នែកខាងឆ្វេង បណ្តាលអោយជាំ បន្ទាប់មកទើបឈ្មោះ ភ ឈន និង ឈ្មោះ ភ ចន នាំគ្នាត្រលប់មកផ្ទះខ្លួនវិញ ។

-បានឃើញដីកាបញ្ជូនរឿងលេខ ០០២/១៩៩៣ ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ របស់អធិការដ្ឋាននគរបាលស្រុកតាខ្មៅ ។

-បានឃើញវិញ្ញាបនប័ត្រវេជ្ជសាស្ត្រលេខ ០១៧/៩៣ ក.ប ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៩៣ របស់មន្ទីរពេទ្យជ័យជំនះខេត្តកណ្តាល ។

-បានឃើញកោសល្យវិច័យពេទ្យលេខ ០២៥/៩៣ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥៣ របស់មន្ទីរសុខាភិបាលរដ្ឋធានីភ្នំពេញ ។

-បានឃើញដីកាបញ្ជូនរឿងអោយជំនុំជំរះលេខ ៨៣ ដ.ក.ជ.រ ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៩៥ ។

## <u>នារពលសទនាភារ</u>

-ជនជាប់ចោទឈ្មោះ ភ ចន វត្តមានក្រឡាបញ្ជីអានចម្លើយបញ្ជាក់ថា ខ្លួនត្រូវជាក្មួយរបស់ឈ្មោះ អ សភ កន្លងមកពុំដែលមានទំនាស់ជាមួយគាត់ទេ ។ នៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ វេលាម៉ោង ០៧ព្រឹកខ្លួនបានទៅរៀននៅសាលាពុំបានដឹងថា ម្តាយខ្លួន និង ឈ្មោះ អ សភ ចាក់គ្នាពីរឿងអ្វីទេ ។ លុះប្រហែលម៉ោង ៩:៣០នាទីព្រឹកថ្ងៃដដែល ខ្លួនត្រលប់ពីរៀនមកដល់ផ្ទះឃើញដុំថ្ម និង ដុំដីវាយពាសពេញផ្ទះខ្លួនក៏សួរមីងខ្លួន ឈ្មោះ ៥ គាត់ក៏ប្រាប់ថាមានរឿងទៀតហើយ ។ ខ្លួនក៏ឡើងទៅផ្លាស់ខោអាវស្លៀកក្រមាវិញ ស្របពេលនេះឪពុកខ្លួនក៏ត្រលប់មកធ្វើការវិញគាត់ក៏សួរនាំដឹងរឿងហេតុហើយក៏ទៅផ្ទះឈ្មោះ អ សភ ទទួលពេលនោះម្តាយខ្លួនក៏ត្រលប់មកពីផ្សារដែរ ។ ពេលនោះខ្លួនម្តាយខ្លួន និង ឈ្មោះ ៥ ក៏នៅឈរជិតរបងផ្ទះ អ សភ ស្តាប់ការជជែកគ្នារវាងប៉ាខ្លួន និង ឈ្មោះ អ សភ ចំណែកបងប្អូនរបស់ អ សភ មានគ្នាប្អូនប្រាំនាក់បានចូលមកជជែកជាមួយឪពុកខ្លួនដែរ ព្រមទាំងជេរបញ្ចោរប៉ាត់ណាប៉ាតណីពេលនោះឈ្មោះ ម ជាកូនប្រសារ អ សភ បានស្ទុះមកចាក់ខ្លួនធ្វើអោយរបូតក្រមា ឯឈ្មោះ អ សភ និង បងប្អូនគេទាំងអស់ក៏ស្ទុះវ៉ៃខ្លួនដែរ ។ ពេលកំពុងវាយតប់គ្នានេះខ្លួន ពុំដឹងថា បានវាយត្រូវអ្នកណាខ្លះទេ ព្រោះមនុស្សជាច្រើនច្របូកច្របល់គ្នាពេក ។ បន្ទាប់មកមានអ្នកជិតខាងចូលមកឃាត់ទើបឈប់ឈ្លោះគ្នា ។ ចំពោះរឿងនេះខ្លួននៅក្រោមអាណាព្យាបាលរបស់ឪពុកម្តាយ ដូច្នេះស្រេចលើគាត់ជាអ្នកដោះស្រាយ ។

-ជនរងគ្រោះឈ្មោះ អ សភ បានឆ្លើយបញ្ជាក់ថា កន្លងមកខ្លួនធ្លាប់មានទំនាស់ជាមួយឈ្មោះ អ សថ ម្តងពីរពីរឿងចាក់សំរាម តែពុំបានវាយតប់គ្នាទេ ។ លុះដល់ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩២ ប្រហែលជាម៉ោង ០៧ព្រឹក ខ្លួននៅផ្ទះជាមួយកូន និង កូនប្រសារ ពេលនោះខ្លួនបានប្រមូលសំរាមដុតនៅលើដីឡូតិ៍របស់ខ្លួនទទួលផ្សែងក៏ហុយទៅផ្ទះ អ សថ គេក៏ខឹងជេរខ្លួនយកថ្មិលគប់ខ្លួនតែមិនត្រូវគេ ខ្លួនក៏យកឈើកាយសំរាមទំហំប្រហែលប៉ុនមេជើងបុកទៅវិញ តែមិនត្រូវដែរ បន្ទាប់មកក៏ជេរបញ្ចោរគ្នាទៅវិញទៅមក ហើយថែមយកដុំដីគប់ទៅគប់មកទៀត ក្រោយមកទើបឈ្មោះយាយ អឿន ចូលមកឃាត់ទាំងសងខាងក៏បែកគ្នាឈប់ឈ្លោះគ្នា រួចហើយខ្លួនក៏ទៅផ្សារ ។ លុះដល់ម៉ោងប្រហែល ១០ថ្ងៃដដែល ស្រាប់ឃើញឈ្មោះ ភ ឈន ជាប្តី អ សថ និង ឈ្មោះ ភ ចន ជាកូនបានមកដល់ផ្ទះខ្លួន ហើយសួររកអ្នកប្រកាសសង្គ្រាម ខ្លួនក៏និយាយថា ប្រកាសសង្គ្រាមអី រួចក៏ជជែកគ្នាចុះឡើងៗ ស្រាប់តែឈ្មោះ ភ ចន ជាកូនស្ទុះចូលមកថា អាណាចង់ប្រកាសសង្គ្រាមចេញមុខមក ខ្លួនក៏ថា អញនិយាយជាមួយចាស់ៗទេ ស្រាប់តែឈ្មោះ ភ ចន នេះស្ទុះមកដាល់ខ្លួនពីរដៃជួនៗគ្នាចំភ្នែកខាងឆ្វេង បណ្តាលអោយហើមជាំមួយរំពេច ។ ក្រោយពីឈ្លោះគ្នាហើយខ្លួន

បានទៅពេទ្យជ័យជំនះអោយព្យាបាលរាល់ថ្ងៃ តែពុំបានសំរាកនៅពេទ្យទេ ។ ចំពោះរឿងនេះខ្លួនសុំអោយជនល្មើស សងថ្លៃព្យាបាលរបួស និង កិត្តិយសចំនួន ០១លានរៀល ។

-ឈ្មោះ ភ ឈន ជាសាក្សីបំភ្លឺត្រូវជាឪពុកជនជាប់ចោទបានឆ្លើយបញ្ជាក់ថា កាលប្រពន្ធខ្លួនឈ្លោះគ្នាជាមួយឈ្មោះ អ សភ លើកទី ១ ពេលនោះខ្លួនពុំបានដឹងទេ លុះដល់ម៉ោងប្រហែល១០ព្រឹក គឺនៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩២ នោះខ្លួនត្រលប់មកពីធ្វើការវិញ ក៏ឃើញដុំថ្មនៅរាយពេញផ្ទះខ្លួនសួរកូនឈ្មោះ ភ ចន ថា ហេតុអ្វីវា ឆ្លើយថា មិនដឹង ទើបមកពីរៀន ពេលនោះខ្លួនក៏ទៅផ្ទះឈ្មោះ អ សភ ដើម្បីសួរនាំរឿងហេតុអីបានជាប្រកាសសង្រ្គាមទាំងព្រឹក ស្រាប់តែក្រុមគ្រួសារគេបានមកព្រួតគ្នាជេរបញ្ចោរគ្រួសារខ្លួន ពេលនោះកូនខ្លួនឈ្មោះ ភ ចន រត់ចូលមកជាមួយគ្នា នោះកូនប្រសាររបស់ អ សភ ឈ្មោះ ឆ ទត បានស្ទុះមកធាក់កូនខ្លួន០១ជើងចំពង បន្ទាប់មកគ្រួសារ អ សភ មាន គ្នា ០៤-០៥នាក់មកព្រួតគ្នាវាយកូនរបស់ខ្លួន ពេលនោះកូនរបស់ខ្លួនក៏វាសដៃ ទៅត្រូវចំភ្នែករបស់ អ សភ ហើយខ្លួន ក៏អូសដៃកូនមកផ្ទះវិញ ស្របពេលដែលប្រពន្ធខ្លួនត្រលប់មកពីផ្សារវិញ ក៏ស្ទុះទៅមើល ស្រាប់តែត្រូវគ្រួសារ អ សភ ព្រួតគ្នាវាយបណ្តាលអោយត្រូវពោះ ។

-ឈ្មោះ អ សឋ ហៅ ឆិភ ជាសាក្សីបំភ្លឺត្រូវជាម្តាយរបស់ជនរងគ្រោះបានឆ្លើយបញ្ជាក់ថា នៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១០០២ ម៉ោងប្រហែល ០៧ព្រឹកឈ្មោះ អ សភ បានយកសំរាមមកដុតហុយចូលផ្ទះរបស់ខ្លួន១ ក៏ហៅប្រាប់ កុំអោយដុត ស្រាប់តែឈ្មោះ អ សភ យកឈើដែលកាយសំរាមនោះមកបុកពោះរបស់ខ្លួន តែចំបញ្ជិតខ្លួនក៏រុញឈើនោះ ត្រលប់ទៅវិញ តែមិនត្រូវទេពេលនោះមានការជេរបញ្ចោរគ្នាយ៉ាងខ្លាំង បន្ទាប់មកឈ្មោះ អ សភ បានយកដុំដីមកចោល ខ្លួនបណ្តាលអោយត្រូវចំពោះ ចំខ្នង និង ចង្កេះ ។ ដែលពេលនោះខ្លួនកំពុងមានផ្ទៃពោះ ០៣ខែផង ។ ក្រោយមកអ្នកជិត ខាងចូលមកឃាត់ ទើបឈប់ឈ្លោះគ្នា ។ លុះដល់ម៉ោងប្រហែលជា ១០ព្រឹកថ្ងៃដដែលប្តីខ្លួន ឈ្មោះ ភ ឈន មកពីធ្វើការ វិញ ក៏ទៅសួរនៅផ្ទះ អ សភ ទទួលពេលនោះខ្លួនក៏ត្រលប់មកពីផ្សារវិញ ឯកូនខ្លួនឈ្មោះ ភ ចន ក៏មកពីរៀនវិញដែរ ក៏នាំគ្នាទៅមើលនៅក្បែររបងផ្ទះ ស្រាប់តែពេលនោះកូនប្រសាររបស់ អ សភ បានស្ទុះមកធាក់កូនខ្លួន១ក៏ស្ទុះចូលទៅវិញ វាសដៃត្រូវចំភ្នែក អ សភ តែម្តង ។ បន្ទាប់មកអ្នកជិតខាងចូលឃាត់ ទើបឈប់ឈ្លោះគ្នា ។ ក្រោយពេលកើត ហេតុបានពីរថ្ងៃ គឺនៅថ្ងៃទី ២០ ខែ ធ្នូ ខ្លួនបានទៅពេទ្យសម្ភពក្រុង ទើបដឹងថា រលូតកូន ខ្លួនក៏សំរាកពេទ្យមួយអាទិត្យ ទើបចេញ ។ ចំពោះរឿងនេះខ្លួនសំណូមពរអោយតុលាការសំរេចទៅតាមច្បាប់ ។

-ឈ្មោះ ស ចន ត្រូវជាសាក្សីបានឆ្លើយបញ្ជាក់ថា នៅពេលកើតហេតុលើកទី១ ខ្លួនពុំដឹងទេ លុះដល់លើកទី២ ប្រហែលម៉ោង ១០ព្រឹកថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩២ ខ្លួនលឺគេជេរបញ្ចោរគ្នា ខ្លួនក៏រត់ទៅមើលឃើញគ្រួសាររបស់ឈ្មោះ អ សឋ ចោលដុំថ្មមកលើគ្រួសារឈ្មោះ អ សភ ដែលត្រូវជាម្តាយមីងរបស់ខ្លួនពេលនោះក៏បានរើសដុំថ្មគប់ទៅវិញ តែ មិនត្រូវអ្នកណាទេ ក្នុងពេលនោះដែរ ខ្លួនឃើញភ្នែករបស់មីងខ្លួនខាងឆ្វេងឡើងជាំ ។

-ឈ្មោះ អ ចឋ ជាសាក្សីបានឆ្លើយបញ្ជាក់ច្បាស់ថា នៅថ្ងៃកើតហេតុខ្លួនមិនចាំថ្ងៃ ខែ ទេប្រហែលជា ម៉ោង១០ព្រឹកខ្លួនកំពុងដាំបាយ ស្រាប់តែលឺសូរមាត់ជជែកគ្នា រវាងបងស្រីរបស់ខ្លួនឈ្មោះ អ សភ និង ឈ្មោះ អ សឋ ខ្លួនក៏រត់ទៅមើល ពេលទៅដល់ខ្លួនឃើញឈ្មោះ ភ ចន ជាកូនរបស់ឈ្មោះ អ សឋ បានស្ទុះរត់ចេញពីរបងផ្ទះមកវាយបង ស្រីខ្លួនឈ្មោះ អ សភ មួយដៃចំភ្នែក ហើយក៏រត់ចូលទៅក្នុងរបងផ្ទះគេវិញ ។

-ឈ្មោះ រ ច ត្រូវជាសាក្សីបានឆ្លើយបញ្ជាក់ច្បាស់ថា នៅថ្ងៃកើតហេតុ គឺថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩២ ពេល ដែលភាគីទាំងពីរឈ្លោះលើកទី ១ ខ្លួនបានចូលទៅឃាត់ ក៏ឈប់ឈ្លោះម្តងហើយ ។ ដល់ឈ្លោះលើកទី ២ ខ្លួនពុំបាន ឃើញឈ្មោះ អ សភ វាយ ឬ បុកចំពោះបណ្តាលអោយរលូតកូននោះទេ ខ្លួនគ្រាន់តែចូលទៅឃាត់ប៉ុណ្ណោះ ។

-ឈ្មោះ ឆ ទត ជាសាក្សីបំភ្លឺបានឆ្លើយបញ្ជាក់ថា ខ្លួនត្រូវជាកូនប្រសាររបស់ឈ្មោះ អ សភ កាលពី

ពេលកើតហេតុនោះ ខ្លួនបានវាយឈ្មោះ ភ ចន នេះ គ្រាន់តែចូលទៅឃាត់ប៉ុណ្ណោះ ។

-ឈ្មោះ ៣ ផល ជាសាក្សីបានឆ្លើយបញ្ជាក់ថា កាលពីថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩២ ប្រហែលម៉ោង ១០ព្រឹក ខ្លួនបានឃើញឈ្មោះ ភ ឈន ទៅសួរឈ្មោះ អ សភ នៅផ្ទះថា តើអ្នកណាចង់ប្រកាសសង្គ្រាម ឈ្មោះ អ សភ ក៏ឆ្លើយថា បើចង់ដឹងទៅសួរប្រពន្ធឯងទៅដឹងហើយ ពេលនោះឈ្មោះ ភ ចន ជាកូនក៏បានស្ទុះមកវៃឈ្មោះ អ សភ តែម្តង ។

-ឈ្មោះ រ ច ជាសាក្សីបានឆ្លើយបញ្ជាក់ថា កាលពីថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩២ ប្រហែលម៉ោង ១០ព្រឹកខ្លួនបានឃើញឈ្មោះ អ សភ និង ឈ្មោះ ភ ឈន ទាស់គ្នា ពេលនេះឈ្មោះ ភ ចន ជាកូនបានចូលមកនិយាយថា អ្នកណាចង់ប្រកាសសង្គ្រាមចូលមក ហើយស្រាប់តែស្ទុះមកដាល់ឈ្មោះ អ សភ តែម្តង ។ បន្ទាប់មកអ្នកទាំងសងខាងបែកគ្នានៅផ្ទះរៀងខ្លួនហើយនៅតែបន្តជេរបញ្ចោរគ្នា និង រើសដុំថ្ម និង ដុំដីគប់គ្នាទៅវិញទៅមកទៀត ។

## <u>ព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋានទោសថា</u> :

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ ជនរងគ្រោះ និង សាក្សី ព្រមទាំងភស្តុតាងទាំងអស់រួចមកឃើញថា ជនជាប់ចោទឈ្មោះ ភ ចន ជាមនុស្សចិត្តឆេវឆាវ ខ្វះការពិចារណាដែលដល់ បានវៃឈ្មោះ អ សភ មួយដៃចំភ្នែកខាងឆ្វេងបណ្តាលអោយរបួស ។ ម្យ៉ាងទៀតភាគីជំលោះទាំងសងខាងជាមនុស្សខ្វះការពិចារណា និង យោគយល់គ្នាមានផ្ទះនៅជិតគ្នា បែរជាបង្កជំលោះធ្វើអោយផ្អើលអស់អ្នកជិតខាង អំពើនេះធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយសាធារណៈ និង នីត្យានុកូលភាពរបស់សង្គម ធ្វើអោយប្រជារាស្ត្រទូទៅស្អប់ខ្ពើមបំផុត ។ ចំពោះលិខិតកោសល្យវិច័យរបស់មន្ទីរពេទ្យក្រុងភ្នំពេញនោះ ក្រោយពីបានពិនិត្យគ្រប់ជ្រុងជ្រោយរួចមកឃើញថា ពុំសមស្របឡើយ ដោយសាម៉ីខ្លួនឈ្មោះ អ សផ ឆ្លើយពុំមានភាពស្មោះត្រង់មួលបង្កាច់អ្នកដទៃ ព្រះរាជអាជ្ញាសុំធ្វើការបដិសេធចោលពុំទទួលស្គាល់ឡើយ ។ ក្នុងរឿងនេះព្រះរាជអាជ្ញានៅតែធ្វើការចោទប្រកាន់លើឈ្មោះ ភ ចន ពីបទ បង្ករបួសស្នាម ដដែល ។ ដូច្នេះសុំអោយលោកចៅក្រមជំនុំជំរះសំរេចសេចក្តីទៅតាមច្បាប់ ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយជនរងគ្រោះ

-ក្រោយពីបានស្តាប់ចម្លើយសាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សំដីចុងក្រោយបង្អស់របស់ជនជាប់ចោទ

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## <u>តុលាការយល់ឃើញថា</u>

-ការអវត្តមានរបស់ជនជាប់ចោទ ពុំបណ្តាលអោយប៉ះពាល់ដល់នីតិវិធីនៃការជំនុំជំរះនោះទេ ហើយព្រះរាជអាជ្ញាក៏មានការយល់ព្រមផងដែរ ។

-យល់ឃើញថា ជនជាប់ចោទឆ្លើយគ្មានភាពស្មោះត្រង់ ។

-យល់ឃើញថា ជនជាប់ចោទឈ្មោះ ភ ចន ជាមនុស្សពេញវ័យមានកំលាំងមាំមួន និង ស្មារតីគ្រប់គ្រាន់នៅប្រព្រឹត្តបទល្មើស ។

-យល់ឃើញថា ជនជាប់ចោទជាមនុស្សឆេវឆាវ ពេលលី និង ថា គ្រួសារខ្លួនមានជំលោះបន្តិចបន្តួចជាមួយ

ឈ្មោះ អ សក ជាម្ដាយមីង ពុំសួរនាំរកហេតុផលអ្វីទេ បែរជាស្ទុះទៅដាល់មួយដៃបណ្ដាលអោយជនរងគ្រោះជាំភ្នែកខាងឆ្វេង ។

-យល់ឃើញថា ក្រោយពីមានរបួសហើយជនរងគ្រោះឈ្មោះ អ សក បានចូលទៅសំរាកនៅមន្ទីរពេទ្យជ័យជំនះ ខេត្តកណ្ដាល ដោយមានស្លាកស្នាមដូចតទៅ :

+ ហើមជាំនៅរង្វង់ភ្នែកឆ្វេង និង ថ្ងាស

+ មានឈាមនៅក្នុងគ្រាប់ភ្នែកឆ្វេង

+ ភ្នែកថយចុះ ៦/១០

+ចូលសំរាកពេទ្យថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩២ ចេញថ្ងៃទី ១១ ខែ មករា ឆ្នាំ ១៩៩៣ សំរាកព្យាបាលចំនួន ២៣ថ្ងៃ ។

-យល់ឃើញថា វិញ្ញាបនប័ត្រវេជ្ជសាស្ត្ររបស់មន្ទីរពេទ្យក្រុងភ្នំពេញលេខ ០២៥-៩៣ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៣ ដែលពិនិត្យលើឈ្មោះនាង អ សឆ បញ្ជាក់ថា រលូតកូនដោយមានកូន ០១ខែកន្លះនោះ ព្រះរាជអាជ្ញាបានស្នើសុំធ្វើការបដិសេធ ។ សំណើនេះមានលក្ខណៈសមហេតុសមផល ដោយចម្លើយនាង អ សឆ ឆ្លើយគ្មានការស៊ីសង្វាក់គ្នា ។

-យល់ឃើញថា មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់បញ្ជាក់ថា ជនជាប់ចោទឈ្មោះ ភ ចន ពិតជាបានដាល់នាង អ សក ជាជនរងគ្រោះប្រាកដមែន ប្រព្រឹត្តនៅភូមិព្រែកឬស្សី ឃុំព្រែកឬស្សី ស្រុកតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩២ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្ដន្ទាទោស តាមបញ្ញត្តិមាត្រា ៤១, ៦៨, ៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

-យល់ឃើញថា ជនជាប់ចោទពិតជាបានវាយទៅលើជនរងគ្រោះប្រាកដមែន ប៉ុន្តែបើពិនិត្យទៅលើយុវភាពឃើញថា នៅក្មេងទើបតែអាយុ ១៩ឆ្នាំប៉ុណ្ណោះ ដូច្នេះនៅមានចិត្តឆេវឆាវ ធ្វើអ្វីពុំសូវពិចារណា អោយបានវែងឆ្ងាយច្រើនតែធ្វើឡើងតាមកំហឹងរបស់ខ្លួន ហើយការប្រព្រឹត្តក៏ជាលើកទី ១ ម្យ៉ាងទៀតជនរងគ្រោះបានជាសះស្បើយអស់ហើយពុំបណ្ដាលអោយពិការនូវកាយសម្បទាណាមួយឡើយ ។

-យល់ឃើញថា ជនរងគ្រោះសុំទាមទារជម្ងឺចិត្តក្នុងការព្យាបាលជម្ងឺចំនួន ០១លានរៀល តុលាការ និង លើកយកទៅពិចារណាតាមភាពជាក់ស្តែង ។

## ហេតុដូច្នេះសំរេច :

១-បដិសេធចោលជាអសារបង់នូវវិញ្ញាបនប័ត្រវេជ្ជសាស្ត្ររបស់មន្ទីរពេទ្យក្រុងភ្នំពេញលេខ ០២៥-៩៣ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៣ ដែលពិនិត្យលើនាង អ សឆ ។

២-ផ្ដន្ទាទោសជនជាប់ចោទឈ្មោះ ភ ចន ហៅ ភ ភេទប្រុស អាយុ ១៩ឆ្នាំ ដាក់ពន្ធនាគារកំបាំងមុខកំណត់ ០៣ខែ ប៉ុន្តែទោសនេះត្រូវព្យួររយៈពេលសាកល្បង ០៥ឆ្នាំ ។ ទោសព្យួរនេះ គិតពីថ្ងៃប្រកាសសាលក្រមពីបទ <u>បង្ករបួសស្នាមដោយចេតនា</u> លើនាង អ សក ប្រព្រឹត្តនៅភូមិព្រែកឬស្សី ឃុំព្រែកឬស្សី (បដិវត្ត) ស្រុកតាខ្មៅ ខេត្តកណ្ដាលពីថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩២ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង <u>ផ្ដន្ទាទោសតាមមាត្រា ៤១, ៦៨, ៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល</u> ។

៣-បង្គាប់អោយជនជាប់ចោទឈ្មោះ ភ ចន ហៅ ភ បង់ជម្ងឺចិត្តទៅជនរងគ្រោះឈ្មោះនាង អ សក

ចំនួន ២០ម៉ឺនរៀល ។ សុំលើសពីនេះលើកចោល ។

៤-បើជនជាប់ចោទគ្មានប្រាក់ធនទណ្ឌគ្រប់ទេ ត្រូវដាក់គុកបង្ខំដល់រូបកាយ ដើម្បីទារប្រាក់ធនទណ្ឌតាមបញ្ញត្តិមាត្រា ៣. ៧ នៃច្បាប់ស្តីពីការដាក់គុកបង្ខំលើរូបកាយក្នុងរឿងព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ១៨ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩២ ។

៥-សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខជនរងគ្រោះ កំបាំងមុខជនជាប់ចោទ ។ ជនរងគ្រោះមានសិទ្ធិប្តឹងឧទ្ធរណ៍រយៈពេល ០២ខែ គិតពីថ្ងៃប្រកាសសាលក្រម ។ ជនជាប់ចោទមានសិទ្ធិប្តឹងទាស់រយៈពេល ១៥ថ្ងៃ គិតពីថ្ងៃទទួលដំណឹង និង សិទ្ធិប្តឹងឧទ្ធរណ៍រយៈពេល ០២ខែ ដោយគិតពីថ្ងៃផុតកំណត់នៃការប្តឹងទាស់ ។

**ចៅក្រមជំនុំជំរះ**

[redacted]

---

សេចក្តីនេះ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលក្រមស្ថាប័នមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ នឹងកងកំលាំងប្រដាប់អាវុធត្រូវជួយអនុវត្តសាលក្រមនេះ ឱ្យបានសំរេច ។

*កណ្តាល. ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ១៩៩៥*

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានតុលាការខេត្តកណ្តាល**

[redacted]